**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ........................................................

# មតិសំណេះសំណាល
# លោកជំទាវបណ្ឌិត ជា សិរី អគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងពិធីអបអរសាទរដល់សិស្សថ្នាក់ទី១២ ដែលប្រឡងជាប់ជាស្ថាពរ
# សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំសិក្សា ២០២៤-២០២៥
# នៅស្រុកសន្ទុក ខេត្តកំពង់ធំ

ថ្ងៃពុធ ៩កើត ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ត្រូវនឹងថ្ងៃទី១ ខែតុលា ឆ្នាំ២០២៥

ជាបឋម សូមគោរព

- ឯកឧត្តម លោកជំទាវ លោក-លោកស្រី ក្រុមការងារថ្នាក់កណ្តាល ថ្នាក់ខេត្ត ថ្នាក់ស្រុក
- លោក **ឡុង គីសឹង** អភិបាលស្រុកសន្ទុក
- លោកនាយក-នាយករង លោកគ្រូ-អ្នកគ្រូ ប្អូនៗសិស្សានុសិស្សទាំងអស់ ជាទីស្រលាញ់រាប់អាន

ថ្ងៃនេះ ខ្ញុំមានក្តីសោមនស្សរីករាយជាអតិបរមា ដោយបានចូលរួមក្នុងពិធីអបអរសាទរដល់សិស្សានុសិស្ស ដែលបានប្រឡងជាប់ជាស្ថាពរសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឆ្នាំសិក្សា ២០២៤-២០២៥ សរុបចំនួន ៥១៦ រូប ក្នុងនោះមានស្រីចំនួន ៣១៥រូប នៅក្នុងវិទ្យាល័យទាំង៣ របស់ស្រុកសន្ទុកយើងនេះ រួមមានៈ វិទ្យាល័យហ៊ុន សែន ភ្នំសន្ទុក វិទ្យាល័យតាំងក្រសាំង និងវិទ្យាល័យកំពង់ថ្ម។ ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះ ជោគជ័យរបស់ក្មួយៗ ដែលពិតជាបានបង្ហាញពីស្មារតីតស៊ូ អត់ធ្មត់ ខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់រៀន សូត្ររហូតសម្រេចបានលទ្ធផលជាវិជ្ជមាននេះ។ ការខិតខំព្យាយាមរៀនសូត្រកន្លងមកនេះ ពិតជាបាននាំមក នូវកិត្តិយស និងសេចក្តីថ្លៃថ្នូរជូនក្រុមគ្រួសារក្មួយៗ និងសង្គមជាតិយើង ជាពិសេស ស្រុកសន្ទុកយើងទាំងមូល។

ជាមួយគ្នានេះ ខ្ញុំក៏សូមលើកទឹកចិត្តចំពោះក្មួយៗដែលមិនទទួលបានជោគជ័យសម្រាប់ការប្រឡង ឆ្នាំនេះ ត្រូវតស៊ូប្រឹងប្រែងរៀនសូត្របន្តទៀតកុំអស់សង្ឃឹម និងបោះបង់ចោលត្រឹមនេះ ហើយត្រូវចាត់ទុកថា ឆ្នាំនេះបានផ្តល់នូវបទពិសោធថ្មីមួយដល់ក្មួយៗ សម្រាប់បន្តប្រឹងប្រែង និងត្រៀមខ្លួនប្រឡងជាថ្មីម្តងទៀត នៅឆ្នាំសិក្សាក្រោយ។ ស្របពេលជាមួយគ្នានេះ ក្មួយៗក៏អាចប្រើឱកាសនេះ ដើម្បីចូលរៀនជំនាញវិជ្ជាជីវៈ ឬ បន្តសិក្សាកម្រិតផ្សេងៗ ដើម្បីបន្តអភិវឌ្ឍចំណេះដឹង និងជំនាញ ក្នុងការឈានទៅចាប់យកអាជីពច្បាស់លាស់ នៃការកសាងអនាគតដ៏ភ្លឺស្វាងក្រោមម្លប់សន្តិភាព។

ខ្ញុំសូមចូលរួមអបអរសាទរជាមួយមាតាបិតា អាណាព្យាបាល និងលោកគ្រូ-អ្នកគ្រូរបស់ក្មួយៗ ចំពោះ



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

សមិទ្ធផលនៃការសិក្សាដ៏ល្អប្រសើរដែលលោក ឡុង គីសឹង អភិបាលស្រុកសន្ទុក បានធ្វើរបាយការណ៍មុននេះ។ នៅទូទាំងខេត្តកំពង់ធំយើង មានបេក្ខជនប្រឡងសរុបចំនួន ៥.៧៩៥រូប ស្រី ៣.៣១៩រូប ក្នុងនោះ ស្រុកសន្ទុកយើងមានបេក្ខជនប្រឡងសរុបចំនួន ៥៨៥រូប ស្រី ៣៤១រូប ជាលទ្ធផលនៃការខិតខំរបស់ក្មួយៗ អ្នកដែលបានប្រឡងជាប់ជាស្ថាពរថ្នាក់ខេត្តមានចំនួន ៥.១៣៣រូប ស្រី ៣.០៣៧រូប ដែលស្រុកសន្ទុកយើងមានបេក្ខជនប្រឡងជាប់ជាស្ថាពរចំនួន ៥១៦រូប ស្រី ៣១៥រូប។ ជាមោទនភាពផងដែរ ដែលយើងមានក្មួយៗចំនួន ៧រូប ស្រី ៥រូប មកពីវិទ្យាល័យតាំងក្រសាំង និងវិទ្យាល័យកំពង់ថ្ម ទទួលបាននិទ្ទេស A សូមអបអរសាទរ។ លទ្ធផលរបស់ក្មួយៗទាំងអស់គ្នា ពុំមែនជាជោគវាសនាទេ ប៉ុន្តែគឺជាការវាស់ស្ទង់សមត្ថភាពពិតៗរបស់ក្មួយៗ។

ក្នុងន័យនេះ ខ្ញុំមានក្តីសោមនស្សក្នុងការជម្រាបជូនក្មួយៗ និងមាតាបិតា-អាណាព្យាបាលថា **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** និងលោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត** បានប្រកាសផ្តល់អាហារូបករណ៍ដ៏ថ្លៃថ្លារបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** (អ.ម.ត) ចំនួន ៤.៥៧០ កន្លែង សម្រាប់ថ្នាក់សញ្ញាបត្របច្ចេកទេស បរិញ្ញាបត្ររង និងបរិញ្ញាបត្រ ឆ្នាំសិក្សា ២០២៥-២០២៦ ដោយឆ្លងកាត់ការប្រឡង និងមិនឆ្លងកាត់ការប្រឡង។

**ឯកឧត្តម លោកជំទាវ លោក-លោកស្រី លោកគ្រូ-អ្នកគ្រូ និងក្មួយៗទាំងអស់ ជាទីមេត្រី!**

ក្រោមដំបូលសន្តិភាពដែលជាមរតកដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងក្រោមការដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** រាជរដ្ឋាភិបាលនីតិកាលថ្មីបាននិងកំពុងដឹកនាំប្រទេសជាតិយើងប្រកបដោយភាពស្វាហាប់ និងសមាហរណកម្មជាតិនិងអន្តរជាតិ ដើម្បីបន្តបេសកកម្មដ៏ពិសិដ្ឋរបស់រាជរដ្ឋាភិបាលនីតិកាលចាស់ក្នុងការរក្សាឱ្យបានសុខសន្តិភាព ដែលជាខឿនជានាសេចក្តីសុខរបស់ប្រជាពលរដ្ឋ ជំរុញដល់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍបានសមិទ្ធផលថ្មីៗបន្តទៀត ដើម្បីឆ្លើយតបសេចក្តីត្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋ។

ស្របតាម "យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១" នេះ កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ រាជរដ្ឋាភិបាលរបស់ **សម្តេចធិបតី ហ៊ុន ម៉ាណែត** បានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនូវកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសសម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេស ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ន និងអនាគត។ ដូច្នេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានកំណត់យកវិស័យអាទិភាពចំនួន ១០ និងមុខជំនាញចំនួន ៣៨ ដើម្បីបណ្តុះបណ្តាលយុវជនគោលដៅចំនួន ១លាន៥សែននាក់ ដោយមិនបង់ថ្លៃ និងទទួលប្រាក់ឧបត្ថម្ភ ២៨ម៉ឺនរៀលក្នុងមួយខែ។ គិតត្រឹមខែសីហា ឆ្នាំ២០២៥ អ្នកដែលបានចុះឈ្មោះចូលរៀនប្រមាណ ១៤ម៉ឺននាក់ និងសិស្សកំពុងសិក្សាមានចំនួនប្រមាណ ៣,១ម៉ឺននាក់ និងបានបញ្ចប់ការសិក្សាមានប្រមាណ ៥,៦ម៉ឺននាក់ ហើយអ្នកដែលទទួលបានការងារបន្ទាប់ពីបញ្ចប់ការសិក្សាមានប្រមាណ ២,៩ម៉ឺននាក់។ ក្នុងន័យនេះ **សម្តេចមហាបវរធិបតី** ក៏បានអំពាវនាវយុវជនទូទាំងប្រទេសឱ្យចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ឱ្យឈានដល់គោលដៅ ១លាន ៥សែននាក់ ក្នុងរយៈពេល៥ឆ្នាំ ដើម្បីបង្កើតឱកាសការងារ និងសាងក្តីសង្ឃឹមថ្មីដល់យុវជនកម្ពុជា។ ទន្ទឹមនេះ រាជរដ្ឋាភិបាលបានកំណត់យកថ្ងៃទី១៥ ខែមិថុនា ជារៀងរាល់ឆ្នាំសម្រាប់ប្រារព្ធទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្នុងគោលបំណងដើម្បីលើកកម្ពស់គុណភាព គុណតម្លៃ និងកិត្តិនាមនៃការអប់រំនេះ តាមរយៈការផ្សព្វផ្សាយទៅដល់សិស្សានុសិស្ស និស្សិត យុវជន មាតាបិតា អាណាព្យាបាល និងវិស័យឯកជនឱ្យបានយល់ដឹងអំពីសារៈសំខាន់នៃ "ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

TVET" ក្នុងការជំរុញការបណ្តុះបណ្តាលកម្លាំងពលកម្មជំនាញ ប្រកបដោយគុណភាព និងប្រសិទ្ធភាពដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារទាំងក្នុងនិងក្រៅប្រទេស។

## ខ្លឹមសារជំនួយស្មារតីបន្ថែម

១/- តាមរយៈសិក្ខាសាលាស្ដីពី **ការរៀបចំផែនការអាជីព និងការជ្រើសរើសជំនាញសិក្សា** កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៥ កន្លងទៅ ខ្ញុំសង្ឃឹមថា ក្មួយៗ បានទទួលជាគតិច្រើន ជាទុនក្នុងការពិចារណា និងសម្រេចចិត្តបន្តការសិក្សាលើមុខជំនាញណាមួយ ដែលសមស្របនឹងចំណង់ចំណូលចិត្ត បុគ្គលិកលក្ខណៈ និងទេពកោសល្យរបស់ខ្លួន ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការការងារជាក់ស្តែងផងដែរ។ ជាសាររំលឹកជាថ្មីម្តងទៀត សូមក្មួយៗកុំសម្រេចចិត្តជ្រើសរើសជំនាញ ឬការរៀនសូត្រនៅមហាវិទ្យាល័យ តាមសង្សារ ឬមិត្តភក្តិ។ ខ្ញុំជឿថា ធ្លាប់មានករណីនេះកើតឡើង ឧទាហរណ៍ ដឹងថាសង្សារសម្រេចចិត្តទៅរៀនពេទ្យ ដូច្នេះដើម្បីបានជួបមុខគេរាល់ថ្ងៃ ក៏សម្រេចចិត្តទៅរៀនពេទ្យដែរ ទាំងដែលខ្លួនឯងមិនដែលចូលចិត្តពេទ្យផងនោះ។

២/- បើក្មួយៗបានសម្រេចជ្រើសរើសជំនាញដែលខ្លួនស្រលាញ់រួចហើយ ត្រូវមានស្មារតីប្តេជ្ញាចិត្តប្រឹងឱ្យអស់លទ្ធភាព។ បើចេះអីមួយ ត្រូវចេះឱ្យច្បាស់និងប្រាកដ ទើបអាចរកការងារបានល្អ។ **សម្តេចធិបតី**ក៏ធ្លាប់មានប្រសាសន៍ថា រៀនឱ្យចប់ រៀនឱ្យចេះ និងឱ្យមានការងារធ្វើ។

៣/- ក្មួយៗ រៀនចប់ប្រឡងជាប់បាក់ឌុប ដែលទទួលបានការបណ្តុះបណ្តាលមូលដ្ឋាន គឺជាធនធានមនុស្សរបស់ប្រទេសជាតិ (Human resource)។ បន្តការសិក្សានៅមហាវិទ្យាល័យ និងទទួលបានការបណ្តុះបណ្តាលជំនាញពិតប្រាកដ គឺក្មួយៗទាំងអស់គ្នាត្រូវបានហៅថា ជាមូលធនមនុស្ស (Human capital) សម្រាប់ប្រទេសជាតិ។ ឧទាហរណ៍ ប្រទេសសិង្ហបុរី អត់មានធនធានធម្មជាតិដូចប្រទេសយើងទេ ប៉ុន្តែ ប្រទេសនេះ សម្បូរទៅដោយ មូលធនមនុស្ស (Human Capital) ធ្វើឱ្យប្រទេសគេមានការរីកចម្រើនយ៉ាងខ្លាំងក្នុងតំបន់អាស៊ីយើងនេះ។

**ឯកឧត្តម លោកជំទាវ លោក-លោកស្រី លោកគ្រូ-អ្នកគ្រូ និងក្មួយៗទាំងអស់ ជាទីមេត្រី !**

ជាថ្មីម្តងទៀត ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ ចំពោះការខិតខំរៀនសូត្ររបស់ក្មួយៗទាំងអស់ និងសូមអរគុណចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារ អាជ្ញាធរដែនដី មាតាបិតា-អាណាព្យាបាល លោកគ្រូ-អ្នកគ្រូ និងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានរួមចំណែកដល់ការសម្រេចបានជោគជ័យរបស់ក្មួយៗទាំងអស់។ ខ្ញុំក៏សូមថ្លែងអំណរគុណជូនចំពោះក្រុមការងារទាំងអស់ ដែលបានចូលរួមសហការរៀបចំកម្មវិធីនាថ្ងៃនេះ ហើយខ្ញុំក៏សូមបង្ហាញនូវក្តីសង្ឃឹមជឿជាក់យ៉ាងមុតមាំថា ក្មួយៗទាំងអស់នឹងជ្រើសរើសជំនាញសិក្សាបន្តឱ្យបានត្រឹមត្រូវ និងខិតខំប្រឹងប្រែងរៀនសូត្របន្តការសិក្សាថ្នាក់ឧត្តមសិក្សា និងថ្នាក់ក្រោយៗទៀត ដើម្បីអភិវឌ្ឍចំណេះដឹងរបស់ខ្លួន ការរីកចម្រើននៅក្នុងគ្រួសារ និងចូលរួមចំណែកអភិវឌ្ឍសង្គម និងប្រទេសជាតិយើង។

ជាមួយគ្នានេះ បន្ទាប់ពីទទួលបានសំណើពីបណ្តាសាលារៀននៅក្នុងស្រុកសន្ទុក ក្រុមការងារធនាគារជាតិនៃកម្ពុជា បានចុះពិនិត្យស្ថានភាពជាក់ស្តែងនៅតាមសាលារៀននីមួយៗ និងបានពិនិត្យឃើញថា សាលារៀនមួយចំនួន មានការខ្វះខាតអគារសិក្សា ហើយអគារដែលមានស្រាប់មានសភាពចាស់ទ្រុឌទ្រោម ហើយខ្លះទៀតជាអគារឈើចាស់ និងជារោងដោល ដែលមានដំបូលនិងជញ្ជាំងធ្លុះធ្លាយ។ ដូច្នេះដើម្បីជួយសម្រួល

ដល់សិស្សានុសិស្សឱ្យមានបន្ទប់សិក្សាសមរម្យ ក៏ដូចជាដើម្បីរួមចំណែកក្នុងការងារសង្គម និងលើកកម្ពស់វិស័យអប់រំ ធនាគារជាតិនៃកម្ពុជា បានឧបត្ថម្ភអគារសិក្សាសាងសង់ថ្មី សរុបមានចំនួន ៩ខ្នង (ស្មើ ៤១បន្ទប់) ព្រមទាំងសាងសង់បន្ទប់ទឹកថ្មី ១ខ្នង និងសាងសង់រោងអាហារ ១ខ្នង សម្រាប់សាលារៀនចំនួន៨។ ចំណែកអគារសិក្សាត្រូវជួសជុល សរុបមានចំនួន ២១ខ្នង ព្រមទាំងជួសជុលបន្ទប់ទឹក ១ខ្នង និងជួសជុលអាហារដ្ឋាន ១ខ្នង សម្រាប់សាលារៀនចំនួន១២។

ទន្ទឹមនេះ ថ្ងៃនេះខ្ញុំ តំណាងធនាគារជាតិនៃកម្ពុជា ក៏បាននាំយកនូវអំណោយ និងប្រាក់ឧបត្ថម្ភ ដើម្បីចែកជូន លោកគ្រូ-អ្នកគ្រូ និងក្មួយៗសិស្សានុសិស្សនៃវិទ្យាល័យទាំង៣ របស់ស្រុកសន្ទុកយើង សរុបប្រមាណ ៥៨៥នាក់ ដែលក្នុងនោះរួមមាន៖

១/- សិស្សនិទ្ទេស A ចំនួន ៧រូប ដោយក្នុងម្នាក់ទទួលបាន៖
- Laptop ចំនួន ១គ្រឿង
- អាហារូបករណ៍សិក្សានៅវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ IBS ១០០%

២/- សិស្សនិទ្ទេស B ចំនួន ២៤រូប ដោយក្នុងម្នាក់ទទួលបាន៖
- អាហារូបករណ៍ថ្លៃសិក្សានៅវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ IBS
- ប្រាក់ឧបត្ថម្ភចំនួន ២០០.០០០រៀល

៣/- សិស្សនិទ្ទេស C ចំនួន ១១៤រូប ដោយក្នុងម្នាក់ទទួលបាន៖
- ប្រាក់ឧបត្ថម្ភចំនួន ១០០.០០០រៀល

៤/- សិស្សនិទ្ទេស D E និង F ចំនួន ៤៤០រូប ដោយក្នុងម្នាក់ទទួលបាន៖
- ប្រាក់ឧបត្ថម្ភចំនួន ៥០.០០០រៀល

៥/- លោកគ្រូ អ្នកគ្រូ បង្រៀនថ្នាក់ទី១២ និងមន្ត្រីការិយាល័យអប់រំចំនួន ៧៥រូប ដោយក្នុងម្នាក់ទទួលបាន៖
- ប្រាក់ឧបត្ថម្ភ ក្រដាសប្រាក់ ២០០.០០០រៀល

៦/- ឧបត្ថម្ភទីស្នាក់ការគណបក្សស្រុក ថវិកាចំនួន ២.០០០.០០០រៀល។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរគណៈអធិបតី លោក-លោកស្រី លោកគ្រូ-អ្នកគ្រូ និងក្មួយៗទាំងអស់ សូមបានប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!!!**